ឯកសារ/N°: C 26/4

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 11 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fuy

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 18 / 11 / 2008
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CA Fuy

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន

# Order on Extension of Provisional Detention
# Ordonnance sur la prolongation de la détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** សហចៅក្រមស៊ើបអង្កេតនៃអង្គ ជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **ខៀវ សំផន**
ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ខៀវ សំផន ក្នុងថេរៈវេលាអតិបរមាចំនួនមួយឆ្នាំ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (C26)

បានឃើញសំណើសុំដោះលែងជនត្រូវចោទឱ្យមានសេរីភាព ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ (C40)

បានឃើញដីកាសម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី ២៨ តុលា ឆ្នាំ ២០០៨ (C40/4)

បានឃើញសេចក្ដីជូនដំណឹងចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួន អំពីគោលបំណងរបស់យើងក្នុងការបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (C26/2)

បានឃើញការតវ៉ាជំទាស់របស់ក្រុមមេធាវីការពារក្ដីរបស់ជនត្រូវចោទ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (C)។

## ការរំលឹកឡើងវិញអំពីនីតិវិធី

១. នាថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានបង្ហាញឈ្មោះ ខៀវ សំផន និងជនសង្ស័យចំនួនបួននាក់ផ្សេងទៀត ថាបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ[1]។

២. នាថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ ខៀវ សំផន អំពីការដាក់ជននេះឱ្យឋិតនៅក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្ស

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ (D3)។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត) និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ (ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមាន ការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិ ទទួលបានការកាត់ទោសដោយយុត្តិធម៌ ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់)[2]។

៣. នាថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បន្ទាប់ពីមានការពិភាក្សាតទល់ សហចៅក្រមស៊ើបអង្កេតបានសម្រេចឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន ខៀវ សំផន ក្នុងថេរៈវេលាអតិបរមាចំនួនមួយឆ្នាំ[3]។

៤. នាថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៧ មេធាវីរបស់ ខៀវ សំផន បានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន[4]។

៥. នាថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ សហមេធាវីការពារក្តីបានធ្វើការសម្រេចដកបណ្តឹងឧទ្ធរណ៍[5]។ ហើយនៅថ្ងៃដដែលនោះ សហមេធាវីការពារក្តីបានដាក់ជូនសហចៅក្រមស៊ើបអង្កេត នូវសំណើសុំដោះលែងឲ្យមានសេរីភាព ដោយផ្អែកលើមូលដ្ឋាននៃវិធាន ៦៤(២) នៃវិធានផ្ទៃក្នុង[6]។

៦. នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព[7]។ សហមេធាវីការពារក្តីបានធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះ នៅថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ ២០០៨[8]។

---

[2] កំណត់ហេតុនៃការជជែកតទល់ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (C25)។

[3] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (C26)។

[4] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ធ្វើនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ (C26/I)។

[5] សេចក្តីជូនដំណឹងអំពីការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ (C26/I/30)។ ការដកបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានទទួលយល់ព្រមដោយអង្គបុរេជំនុំជម្រះ៖ សេចក្តីសម្រេចទាក់ទងនឹងសេចក្តីជូនដំណឹងនៃការដកបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨ (C26/I/30)។

[6] សំណើជាបន្ទាន់សុំដោះលែងឲ្យមានសេរីភាព ចុះថ្ងៃទី ០៨ តុលា ឆ្នាំ ២០០៨ (C40)។


E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឯកសារ/No: C26/4

៧. នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតគ្រោងនឹងធ្វើការបន្តថេរៈវេលានៃការឃុំខ្លួន ខៀវ សំផន ហើយថាពួកគេមានថេរៈវេលា ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ និងតវ៉ា[9]។ នាថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហមេធាវីរបស់ ខៀវ សំផន បានដាក់នូវការកត់សម្គាល់របស់ខ្លួន[10]។

## ការរំលឹកឡើងវិញអំពីច្បាប់ដែលត្រូវអនុវត្ត

៨. វិធាន ៦៣.៦.ក. នៃវិធានផ្ទៃក្នុង ចែងថា "ចំពោះ (...) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (...) សហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបាន ០១ ឆ្នាំ"។

៩. វិធាន ៦៣.៧ នៃវិធានផ្ទៃក្នុង បញ្ជាក់ថា ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងការបន្តការឃុំខ្លួន ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវមានសំអាងហេតុ។

១០. វិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង ចែងថា "សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ បានតែក្នុងលក្ខខណ្ឌដូចខាងក្រោម៖

ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ និង

---

[7] ដីកាសម្រេចបដិសេធសំណើសុំដោះលែងឲ្យមានសេរីភាព (C40/4)។

[8] ការប្រកាសអំពីការធ្វើបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

[9] ការជូនដំណឹង (វិធាន ៦៣.៧) ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ (C26/2)។

[10] សេចក្តីជំទាស់ប្រឆាំងរបស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងការបន្តថេរៈវេលានៃការឃុំខ្លួន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (C26/3)។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី៖

i. រារាំងកុំឱ្យជនត្រូវចោទគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ

ii. ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង

iii. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី

iv. ការពារសន្តិសុខឱ្យជនត្រូវចោទ ឬ

v. រក្សាសណ្តាប់ធ្នាប់សាធារណៈ។

## ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តី

១១. ទឡ្ហីករណ៍ដែលលើកឡើងដោយសហមេធាវីជនត្រូវចោទ នៅក្នុងកំណត់សម្គាល់របស់ខ្លួន មានដូចខាងក្រោម[11]៖

- *"មិនអាចពន្យារការឃុំខ្លួនបានទៀតឡើយ ព្រោះការឃុំខ្លួននេះត្រូវបានធ្វើឡើងតាមទំនើងចិត្ត។ បន្ទាប់ពីបានស៊ើបអង្កេតដោយ ស.ច.ស. អស់រយៈពេលមួយឆ្នាំមក លោក ខៀវ សំផន នៅតែមិនអាចចូលរួមក្នុងការការពារក្តីរបស់គាត់បានយ៉ាងពេញលេញ។ មេធាវីអន្តរជាតិរបស់គាត់នៅតែពុំអាចពិនិត្យមើលសំណុំរឿងស៊ើបអង្កេត ជាភាសាដែលគាត់អាចយល់បានដដែល។ ស្ថានភាពនេះបណ្តាលមកពីអាជ្ញាធរតុលាការ ហើយវាបានបង្កើតជាកំហុសនីតិវិធីស៊ើបអង្កេតទាំងស្រុង។ ដូច្នេះ ការឃុំខ្លួន លោក ខៀវ សំផន ជាបណ្តោះអាសន្ន គឺជាវិធានការតាមទំនើងចិត្តមួយ ហើយមិនអាចត្រូវបានបន្តទៀតបានឡើយ។*

[11] សេចក្តីជំទាស់ប្រឆាំងរបស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងការបន្តរយៈពេលនៃការឃុំខ្លួន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ (C26/3)។



* E.C.C.C * C.E.T.C * CO INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

- *តាមស្ថានភាពនីតិវិធី សច.ស ពុំមានសមត្ថកិច្ចសម្រេចពន្យារការឃុំខ្លួនបណ្តោះអាសន្នបានទេ។ លោក ខៀវ សំផន មានសិទ្ធិត្រូវបានជម្រះក្តីដោយតុលាការមួយដែលឯករាជ្យ និងអព្យាក្រិត្យ។ ដោយឡែក តាមស្ថានភាពនីតិវិធី ស.ច.ស. លែងអាចសម្រេចសេចក្តីលើបញ្ហាឃុំខ្លួនបណ្តោះអាសន្នប្រកបដោយអព្យាក្រិត្យភាពទាំងស្រុងបានទៀតហើយ។ ដូច្នេះ ស.ច.ស. លែងមានសមត្ថកិច្ចទៀតហើយ។*

- *នីតិវិធីបណ្តឹងឧទ្ធរណ៍ដែលកំពុងតែប្រព្រឹត្តទៅ នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងពេលនេះ ពុំអាចញែកឲ្យដាច់ពីគ្នាជាមួយអង្គហេតុនៃមូលហេតុក្នុងរឿងនេះ ហើយ ស.ច.ស លែងអាចបង្គាប់ឲ្យពន្យារការឃុំខ្លួនទៅតាមលក្ខខណ្ឌសម្រាប់សមធម៌នៃរឿងក្តីបានឡើយ។ ដូច្នេះ ស.ច.ស ត្រូវតែផ្អាកដំណើរការរឿងក្តីសិន រហូតដល់មានការអន្តរាគមន៍របស់អង្គបុរេជំនុំលើបញ្ហាកំហុសនីតិវិធីដែលបណ្តាលឲ្យមានអវត្តមាននៃការបកប្រែ"។*

## ហេតុផលនៃសេចក្តីសម្រេច

### ក) អំពី "ចរិតលក្ខណៈរំលោភបំពាន" នៃការឃុំខ្លួនបណ្តោះអាសន្ន

១២. ផ្អែកតាមបណ្តឹងនេះ មេធាវីជនត្រូវចោទ គាំទ្រជាអាទិ៍ថា អនីត្យានុកូលភាពនៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ មិនអាចត្រូវបានបង្ហាញទេ ដោយសារតែភាពមិនរហ័សរហួនរបស់អង្គបុរេជំនុំជម្រះ ហើយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ មិនបានគិតគូរពីបញ្ហានៃការបកប្រែ។

១៣. វាមិនមែនសហចៅក្រមស៊ើបអង្កេតទេ ដែលត្រូវសម្រេចពីចំណុចដែលចង់ដឹងថា តើអាចមានប្រយោជន៍ ឬក៏មិនមានប្រយោជន៍ ប្រសិនដីកាដែលសម្រេចពីការឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ត្រូវបានប្តឹងឧទ្ធរណ៍ដោយមេធាវីការពារក្តី នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដោយបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីជនត្រូវចោទ បានលះបង់ចោលដោយស្ម័គ្រចិត្តនូវ



E.C.C.C * C.E.T.C. * CO INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឯកសារលេខៈ C26/4

សិទ្ធិតវ៉ានៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច គឺជាមួយអង្គបុរេជំនុំជម្រះ អំពីលក្ខខណ្ឌទាំងឡាយនៃការប្រព្រឹត្តទៅនៃនីតិវិធី។

១៤. ជនត្រូវចោទ លើកឡើងផងដែរថា ខ្លួនមិនអាច *"បង្ហាញនូវទស្សនៈយល់ឃើញរបស់ខ្លួនឲ្យបានពេញលេញ ស្របទៅតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង ដោយសារខ្លួនមិនអាចពិភាក្សាពីខ្លឹមសារស៊ីជម្រៅនៃសំណុំរឿងបាន"*។

១៥. សហចៅក្រមស៊ើបអង្កេត បានប្រកាន់ជំហររបស់ខ្លួនពាក់ព័ន្ធនឹងសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងបញ្ហាបកប្រែ ដូចមានខ្លឹមសារនៅក្នុងដីកាសម្រេចដែលមានឈ្មោះដូចគ្នានេះ[12]។ ដោយបណ្តឹងឧទ្ធរណ៍ដែលបានធ្វើឡើងដោយជនត្រូវចោទ មិនមានអានុភាពបង្អង់ការអនុវត្តន៍នោះ ជនត្រូវចោទ បានដឹងយ៉ាងច្បាស់អំពីសិទ្ធិដែលត្រូវអនុវត្ត នៅក្នុងនីតិវិធីដំណាក់កាលនេះទាក់ទិននឹងបញ្ហាបកប្រែសំណុំរឿងព្រហ្មទណ្ឌ។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត នៅក្នុងដំណាក់កាលនេះ អាចបញ្ជាក់សារជាថ្មីទៀតថា សិទ្ធិរបស់ជនត្រូវចោទ មានជាអាទិ៍ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគោរព។

១៦. ជាចុងក្រោយ សេចក្តីសម្រេចអំពីការបន្តថេរៈវេលានៃការឃុំខ្លួន ខៀវ សំផន ជាបណ្តោះអាសន្ន មិនអាស្រ័យទៅលើលទ្ធផលសម្រេចនៃបណ្តឹងឧទ្ធរណ៍ដែលកំពុងតែមានប្រឆាំងនឹងដីកាស្តីពី សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទិននឹងបញ្ហាបកប្រែទេ។ សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចដោះលែងជនត្រូវចោទឲ្យមានសេរីភាព ប្រសិនបើលក្ខខណ្ឌកំណត់នៅក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុង លែងត្រូវបានបំពេញទៀតហើយ[13] និងក្នុងករណីចាំបាច់ ត្រូវគិតពីផលវិបាកទាំងអស់ដែលចេញមកពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់អង្គបុរេជំនុំជម្រះផងដែរ។ ប្រសិននៅរង់ចាំសេចក្តីសម្រេចនេះ ដីកាសម្រេចឃុំខ្លួន ខៀវ សំផន នឹងផុតរយៈពេលកំណត់នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០០៨

[12] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទិននឹងបញ្ហាបកប្រែ (A190), ERN00196931-00196938។

[13] សូមអានវិធាន ៦៤ នៃវិធានផ្ទៃក្នុង ដែលចែងថា ការដោះលែងជនត្រូវចោទឲ្យមានសេរីភាព ត្រូវធ្វើឡើងពេលណាក៏បានងអំឡុងពេលនៃការឃុំខ្លួនជនត្រូវចោទ ប្រសិនបើលក្ខខណ្ឌកំណត់នៅក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុង លែងត្រូវបានបំពេញ។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ហេតុនេះសហចៅក្រមស៊ើបអង្កេត ត្រូវតែពិនិត្យពីលក្ខខណ្ឌនៃការឃុំខ្លួនឡើងវិញ និងសម្រេចពីការបន្តថេរៈវេលានៃការឃុំខ្លួន ដោយមិនអាចរង់ចាំបាន។

## ខ) អំពីភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

១៧. ការកត់សំគាល់របស់មេធាវីការពារក្ដី លើភាពអនាគតិរបស់សហចៅក្រមស៊ើបអង្កេត អាចត្រូវបានវិភាគជា ការធ្វើបណ្ដឹងជំទាស់ចំពោះចៅក្រម ដែលបានចែងនៅក្នុងវិធាន ៣៤។ វិធាន ៣៤(៥) ចែងថា ក្នុងករណីមានបណ្ដឹងជំទាស់ចំពោះចៅក្រមស៊ើបអង្កេតណាម្នាក់ ដែលធ្វើឡើងដោយភាគី[14] ដូចនៅក្នុងករណីនេះ បណ្ដឹងនេះ "ត្រូវដាក់ជូនទៅអង្គបុរេជំនុំជម្រះ"។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត មិនមានសមត្ថកិច្ចសម្រេចលើពាក្យបណ្ដឹងជំទាស់ធ្វើឡើងដោយជនត្រូវចោទ ប្រឆាំងនឹងរូបខ្លួនទេ។

១៨. ប៉ុន្តែ វិធាន ៣៤(១) នៃវិធានផ្ទៃក្នុង ចែងថា "ចៅក្រមអាចដកខ្លួនឯងចេញពីករណីណាមួយដែលចៅក្រមរូបនោះមាន ឬ ធ្លាប់មានផលប្រយោជន៍ផ្ទាល់ខ្លួន (...) ឬមានការពាក់ព័ន្ធដែលអាចធ្វើឱ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ភាពអនាគតិរបស់ចៅក្រមរូបនោះ ឬ អាចបង្កើតឱ្យមានភាពលំអៀង។" សហចៅក្រមស៊ើបអង្កេត ដោយគិតពីយុត្តិសាស្ត្រនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុងរឿងនេះ យល់ឃើញថា វាមានការសន្មតជាមុនថាមានអនាគតិ ហើយក្នុងករណីគ្មានភស្តុតាងផ្ទុយទេ វាជាការចាំបាច់ ត្រូវសន្មតជាមុនថា ចៅក្រម អាចធានាបាននូវស្មារតីសេរីមិនចំណុះឲ្យជំនឿ និងភាពលំអៀងផ្ទាល់ខ្លួន ដែលមិនត្រឹមត្រូវ[15]។

១៩. នៅក្នុងការកត់សំគាល់របស់ខ្លួន សហមេធាវីជនត្រូវចោទ លើកឡើងថា ការប្រគល់តួនាទីទៅឲ្យ

---

[14] ចែងក្នុងវិធាន ៣៤(២) នៃវិធានផ្ទៃក្នុង

[15] សូមអានជាឧទាហរណ៍ TPIY រដ្ឋអាជ្ញា ទល់នឹង Furundzija, រឿងក្ដី លេខ IT-95-17/1-A សាលក្រមតុលាការជំនុំជម្រះដំបូងចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០០ កថា. 196 ; TPIY, រដ្ឋអាជ្ញា ទល់នឹង Dario Kordic និងអ្នកដទៃ, រឿងក្ដី លេខ IT-95-14/2-PT, សេចក្ដីសម្រេច របស់ការិយាល័យ ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៩៨ ទំ. ២



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

ចៅក្រមតែមួយធ្វើការងារស៊ើបសួរផង និងចេញសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នផង នឹងអាចជាកត្តាមួយនាំឲ្យមានការសង្ស័យពីអនាគតិរបស់ចៅក្រមស៊ើបអង្កេត។

២០. នៅចំពោះមុខ អ.វ.ត.ក សមត្ថកិច្ចដើម្បីសម្រេចពីការឃុំខ្លួន ការរក្សាការឃុំខ្លួន និងបន្តការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានប្រគល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត[16]។ ដំណោះស្រាយបែបនេះត្រូវបានអនុម័ត ស្រប និងដូចគ្នានឹងប្រព័ន្ធច្បាប់កម្ពុជាដែលមានជាធរមាន[17]។

២១. លើសពីនេះទៀត ការវិភាគពីគោលការណ៍ដែលមាននៅក្នុងច្បាប់អន្តរជាតិ បង្ហាញថា វាមិនមានដំណោះស្រាយតែមួយគត់ដែលត្រូវបានទទួលស្គាល់ទាក់ទិននឹងអាជ្ញាធរមានសមត្ថកិច្ចក្នុងការសម្រេចលើការឃុំខ្លួនបណ្តោះអាសន្នទេ។ ប៉ុន្តែ វាមានឧបករណ៍គតិយុត្តអន្តរជាតិ ជាច្រើនទាក់ទិននឹងសមត្ថកិច្ចលើបញ្ហាដកហូតសេរីភាព។ ឧទាហរណ៍ មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[18] និងមាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[19] ប្រើប្រាស់ពាក្យពេចន៍ស្ទើរតែដូចគ្នាថា បុគ្គលទាំងឡាយដែលត្រូវបានឃាត់ខ្លួន ឬឃុំខ្លួនត្រូវតែទទួលបាននូវការកាត់ក្តីក្នុងពេលវេលាមួយឆាប់ ដោយចៅក្រម ឬដោយដោយអាជ្ញាធរណាមួយដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ឲ្យបំពេញតួនាទីយុត្តាធិការ។ ដោយអនុវត្តតាមគោលការណ៍នេះ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា សមត្ថកិច្ចក្នុងការសម្រេចលើការឃុំខ្លួន និងក្នុងករណីនេះ ការឃុំខ្លួនបណ្តោះអាសន្នត្រូវប្រគល់ទៅឲ្យចៅក្រម ឬទៅឲ្យអាជ្ញាធរមួយដែលផ្តល់នូវការធានាដូចគ្នា តួយ៉ាងការធានាបាននូវ

---

[16] វិធាន ៦៣ នៃវិធានផ្ទៃក្នុង

[17] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

[18] មាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងនយោបាយ ចែងថា "បុគ្គលទាំងអស់ដែលត្រូវបានឃាត់ខ្លួន ឬឃុំខ្លួនពីបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវតែទទួលបាននូវការកាត់ក្តីក្នុងពេលវេលាមួយឆាប់ ដោយចៅក្រម ឬដោយអាជ្ញាធរណាមួយដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ក្នុងការបំពេញតួនាទីយុត្តាធិការ"។

[19] មាត្រា ៥(៣) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ចែងថា "បុគ្គលទាំងអស់ដែលត្រូវបានឃាត់ខ្លួន ឬឃុំខ្លួន(...) ត្រូវតែទទួលបាននូវការកាត់ក្តីក្នុងពេលវេលាមួយឆាប់ ដោយចៅក្រម ឬដោយដោយអាជ្ញាធរណាមួយដែលមានសមត្ថកិច្ចតាមផ្លូវច្បាប់ក្នុងការបំពេញតួនាទីយុត្តាធិការ"។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

ឯករាជ្យភាព និងអនាគតិ[20]។ ដូចនេះ អាជ្ញាធរ ទទួលបន្ទុកសម្រេចការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានចាត់ទុកថា មិនអាចទុកចិត្តបាន ប្រសិនបើអាជ្ញាធរនេះ អាចចូលរួមនៅក្នុងដំណាក់កាលផ្សេងទៀតនៃនីតិវិធីក្នុងឋានៈជាភាគី ឧទាហរណ៍ក្នុងនាមជាអាជ្ញាធរអ្នកចោទប្រកាន់[21]។

២២. នៅក្នុងរឿងនេះ សហចៅក្រមស៊ើបអង្កេត បំពេញមុខងារជាពិសេស គឺដឹកនាំកិច្ចស៊ើបសួរឲ្យបានល្អ[22] មានន័យថា ធ្វើការស៊ើបអង្កេតលើអង្គហេតុដែលបានបញ្ជូនមកដោយអាជ្ញាធរអ្នកចោទប្រកាន់ និងក្រោយពេលស៊ើបអង្កេតដែលមានលក្ខណៈតទល់គ្នា និងមានលក្ខណៈដាក់បន្ទុក និងដោះបន្ទុក ដោយឯករាជ្យ និងអនាគតិ រួចហើយ ប្រសិនបើមានភស្តុតាងគ្រប់គ្រាន់ ទៅលើជនត្រូវចោទខ្លួនអាចចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ មុខងារនេះ មិនត្រូវមានការភាន់ច្រឡំនឹងមុខងាររបស់ភាគីទេ[23]។ លើសពីនេះទៀត គឺជាការមិនអាចបដិសេធបាន ដែលសហចៅក្រមស៊ើបអង្កេត គឺជា "ចៅក្រម" ដែលបំពេញបាននូវគ្រប់ការធានាផ្សេងៗសម្រាប់មុខងារយុត្តាធិការ តួយ៉ាងការធានាឯករាជ្យភាព និងអនាគតិ[24] ដូចជាចៅក្រមផ្សេងទៀតដែលធ្វើការនៅ

---

20 សូមអាន CEDH ដីកា Schiesser តទល់ Suisse ចុះថ្ងៃទី ៤ ខែធ្នូ ១៩៧៩ សេរី A no 34 ទំព័រ ១៣-១៤ កថា ៣១។ CEDH ដីកា Nikolova តទល់ Bulgarie ចុះថ្ងៃទី ២៥ ខែមីនា ១៩៩៩ បណ្តឹង no 31195/96 កថា ៥៩។ CEDH ដីកា Huber តទល់ Suisse ចុះថ្ងៃទី ២៣ ខែតុលា ១៩៩០ សេរី A no 188 ទំព័រ ១៨ កថា ៤៣។ CEDH ដីកា Brincat តទល់ Italie ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ១៩៩២ សេរី A no 249-A ទំព័រ ១២ កថា ២១។

21 CEDH ដីកា Hood តទល់ Royaume Unie ចុះថ្ងៃទី ១៨ ខែកុម្ភៈ ១៩៩៩ បណ្តឹង no 27267195 កថា ៥៧-៥៨។ CEDH ដីកា Nikolova តទល់ Bulgarie ចុះថ្ងៃទី ២៥ ខែមីនា ១៩៩៩ បណ្តឹង no 31195/96 កថា ៤៩។ CEDH ដីកា Huber តទល់ Suisse ចុះថ្ងៃទី ២៣ ខែតុលា ១៩៩០ សេរី A no 188 ទំព័រ ១៨ កថា ៤៣។ CEDH ដីកា Brincat តទល់ Italie ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ១៩៩២ សេរី A no 249-A ទំព័រ ១២ កថា ២១។

22 មាត្រា ២៣ នៃច្បាប់ ២០០៤ ស្តីពីការបង្កើត អវតក និងមាត្រា ៥ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា។

23 លក្ខខណ្ឌចាំបាច់សម្រាប់យកមកធ្វើការពិចារណា ដោយតុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស គឺ លក្ខណៈសម្បត្តិរបស់ចៅក្រម ដែលជាអ្នកផ្តល់នូវការធានានានាដែលមានភ្ជាប់ជាមួយនឹងមុខងារយុត្តាធិការ គឺមិនមែនវិសមិតភាពនៃមុខងារស៊ើបអង្កេតទេ និងសមត្ថកិច្ចក្នុងរឿងឃុំខ្លួនបណ្តោះអាសន្ន។

24 សូមអានមាត្រា ៥(២) និង មាត្រា ៥(៣) នៃ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា និងមាត្រា ៥នៃ ច្បាប់ ២០០៤ ស្តីពីការបង្កើតអវតក។ ការធានានេះ គឺដូចគ្នានឹងការធានាចំពោះចៅក្រមផ្សេង

អង្គជំនុំជម្រះ។ ដូច្នេះ ប្រការដែលសហចៅក្រមស៊ើបអង្កេត ជាអ្នកសម្រេចឃុំខ្លួន និងបន្តការឃុំខ្លួនបណ្ដោះអាសន្ន ព្រមទាំងជាអ្នកទទួលខុសត្រូវក្នុងការស៊ើបអង្កេតផង មិនមែនជាស្ថានភាពដែលមានលក្ខណៈធ្វើឲ្យប៉ះពាល់ដល់ភាពអនាគតិ ឬ អាចបង្កើតឱ្យមានភាពលំអៀងនោះទេ។

២៣. បន្ថែមលើនេះ ហេតុដែលថាសហចៅក្រមស៊ើបអង្កេត បានសម្រេចរួចមកហើយអំពីអត្ថិភាពនៃហេតុផលសមរម្យ ដែលនាំឲ្យជឿបានថាជនត្រូវចោទបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចដែលបានចោទប្រកាន់ដែលជាលក្ខខណ្ឌចាំបាច់សម្រាប់ការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន មិនបានធ្វើឲ្យសហចៅក្រមស៊ើបអង្កេតគ្មានលទ្ធភាពក្នុងការធ្វើការសម្រេចជាថ្មីដោយអព្យាក្រឹត្យ លើលក្ខខណ្ឌនេះ ដោយពិនិត្យទៅលើការវិវត្តន៍ប្រែប្រួលនៃកាលៈទេសៈទេ។ ព្រោះថា វាចេញពីចរិតលក្ខណៈផ្ទាល់នៃប្រព័ន្ធនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលប្រគល់ទៅឲ្យចៅក្រម ក្នុងការផ្ដល់នូវការធានានានាដែលមានសម្រាប់មុខងារយុត្តាធិការ សមត្ថកិច្ច ដើម្បីសម្រេច និងពិនិត្យឡើងវិញ ដោយអនាគតិ និងគ្រប់ពេលថាលក្ខខណ្ឌនៃការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន នៅតែត្រូវបានបំពេញ ឬទេ។

២៤. លើសពីនេះទៀត ផ្ទុយពីអ្វីមេធាវីការពារក្ដីលើកឡើង[25] គឺទោះបីជាសហចៅក្រមស៊ើបអង្កេតបានសម្រេចនៅក្នុងដីកាមួយផ្សេងដាច់ដោយឡែកលើការបកប្រែ និងបានធ្វើការសន្និដ្ឋានតាមផ្លូវច្បាប់លើបញ្ហានេះរួចហើយក៏ដោយក្ដី ក៏វាមិនមែនជាកត្តាមួយដែលអាចធ្វើឲ្យប៉ះពាល់ដល់ភាពអនាគតិរបស់សហចៅក្រមចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចបន្តថេរៈវេលានៃការឃុំខ្លួនបណ្ដោះអាសន្នទេ[26]។

---

ទៀត ដែលមាននៅក្នុង អវតក (សូមអានមាត្រា ៣ នៃ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា និងមាត្រា ១០ នៃ ច្បាប់ ២០០៤ ស្ដីពីការបង្កើតអវតក។)

[25] នៅក្នុងការកត់សំគាល់របស់ខ្លួន មេធាវីជនត្រូវចោទ លើកឡើងថា នៅក្នុងដីកាបដិសេធការដោះលែងជនត្រូវចោទឲ្យមានសេរីភាព ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេត មិនបានយកចិត្តទុកដាក់ អំពីការដែល លោក ខៀវ សំផន មិនអាចការពារខ្លួនឯងបានលើអង្គច្បាប់ និងបានសម្រេចរួចហើយលើបញ្ហានៃការបកប្រែនោះ ដូច្នេះ សហចៅក្រមស៊ើបអង្កេត មិនអាចពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ និងដោយភាពអនាគតិទេ។

[26] យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានបកស្រាយបន្ថែមថា ទោះបីជាវាអាចទៅរួចចំពោះរឿងដែលថា សេចក្ដីសម្រេចរបស់ចៅក្រម ឬអង្គជំនុំជម្រះ អាចត្រូវបានធ្វើឡើងដោយគ្មានអនាគតិ ក៏ករណីនេះ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ឯកសារ: C26/4

**ហេតុដូច្នេះ**

**សម្រេច** ពន្យារពេលនៃការឃុំខ្លួនបណ្តោះអាសន្ន លោក ខៀវ សំផន សម្រាប់រយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣.៦.ក នៃវិធានផ្ទៃក្នុង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-Juges d'instruction**

MARCEL Lemonde

យូ ប៊ុនឡេង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## FILING INSTRUCTION
*(To Be Completed by Lodging Party)*

| | | | |
|---|---|---|---|
| Case Number: | 002/19-09-2007-ECCC-OCIJ | Date of Document:<br>Date Filed: | 18-11-2008 |
| Document Description: | Order on extension of Provisional Detention of KHIEU Samphan | | |
| Number of Pages: | | Language(s) Filed: Khmer, French | |
| Filed By: | ☐ Chamber ☐ Defense ☐ OCP ☒ OCIJ ☐ Other:<br>Name: Telephone Number: | | |
| Reason For Confidentiality | | | |

Received Stamp

## NOTIFICATION INSTRUCTION
*(To Be Completed by Greffiers Only)*

| | | |
|---|---|---|
| Overall Sequential No.: | Category No.: C26/4 | Page Numbers: |
| Notification To Be Sent To:<br>☒ OCP ☒ OCIJ ☒PTC ☐ All Defense Teams ☐ Defense Office<br>☒ Defense Team For: 002 and Duch team ☐ Press ☐Other:<br>☒Civil party lawyers 002, Prison, Claude Bouchard , DOA, DDOA | | |
| Document Title: | | |
| ☐ Original To CMS Received By: ........................................ Records + Archives | | Dated: |
| Signed: ............[signature]............ Greffier | | Dated: 18-11-2008 |

***CMS Only***

| | | |
|---|---|---|
| ☐ Certified/Safeguard Copy | ☐ Case File Updated | ☐ ZyLAB Updated |
| Signed: ........................................................................ Records + Archives | | |

T070830/0027